# វៀតណាម និង ក្រសួងការបរទេសខ្មែរក្រហម
# បញ្ហាព្រំដែនកម្ពុជា និង វៀតណាម
# ចំឡងពីកំណត់ហេតុដើមមាន ៣ សន្លឹក វាយដោយឆន្ទុសីសេខ

-----------

## *កំណត់ហេតុ*

*ថ្ងៃទី៣-១១-១៩៧៧, ពីម៉ោង ៨ ដល់ ៩, ការធារីវៀតណាម ត្រឹន ស៊ឹន ម៉ិន និង អ្នកបកប្រែ គាវ មិញ មក ជួបជាមួយ ស.ម. ហុង នៅ ប-១ ។ ក្រោយពីការសាកសួរគួរសមបន្តិច ក៏ចាប់ផ្តើមធ្វើការ ។*

*<u>ការធារីវៀតណាម:</u> យើងខ្ញុំមកនេះដើម្បីប្រគល់លិខិតរបស់ក្រសួងការបរទេស នៃសាធារណរដ្ឋសង្គម និយមវៀតណាម ជូនដល់ក្រសួងការបរទេស នៃកម្ពុជាប្រជាធិបតេយ្យ ។ (វានិយាយខ្លឹមសារលិខិតនេះ គឺមិនទទួលខ្សែប្រេវីយេជាព្រំដែនសមុទ្រ ហើយស្នើជួបចរចាគ្នា លិខិតនេះចុះថ្ងៃ២៨-១០-១៩៧៧)*

*<u>ស.ម. ហុង:</u> អរគុណស.ម. ការធារីដែលបានឧទ្ទេសនាមខ្លឹមសារលិខិតនេះ យើងខ្ញុំនឹងជូនដល់ក្រសួងពិនិត្យ ។ តទៅនេះ យើងខ្ញុំសូមបញ្ជាក់អំពីគោលជំហរយើងខ្ញុំដែលបានបោះពុម្ពផែនទីនេះ ។ យើងខ្ញុំក៏បានទទួល ផែនទីដែលស.ម. ប្រគល់មកឲ្យយើងខ្ញុំវិញ ។ សមមិត្តមិនទទួលនេះ គឺជាសិទ្ធិរបស់ស.ម. ។ បើនិយាយពី មុន មកប្រទេសយើងខ្ញុំត្រូវបាត់បង់ទឹកដីជាច្រើនណាស់ ។ នេះជាលទ្ធផលរបស់អាណានិគមនិយមបារាំងវាបាន ចែកឲ្យ ។ អ្នកណាក៏ដោយ បើឈរមើលពីកែបទៅ ក៏សុទ្ធតែនិយាយថាកោះត្រល់ជាកោះរបស់កម្ពុជា ។ បើគិតជាប្រវត្តិសាស្ត្រ និង ភូមិសាស្ត្រ កោះត្រល់ជាកោះរបស់កម្ពុជា តែយើងមិនគិតទេរឿងចាស់ ព្រោះ ចៀសវាងប៉ះពាល់ដល់មិត្តភាព យើងខ្ញុំគិតតែបច្ចុប្បន្នកាល និង ទៅអានាគតកាលទេ ។ ឯខ្សែប្រេវិយេធ្លាប់ បានប្រើប្រាស់យូរណាស់មកហើយ ។ ពីឆ្នាំ១៩៦៦ ប្រត្តិភូរណសិរ្សជាតិរំដោះវៀតណាមខាងត្បូងក៏បាន និយាយជាឱឡារិកជាមួយរដ្ឋាភិបាលសីហនុ ថាចាត់ទុកខ្សែប្រេវិយេជាព្រំដែនរដ្ឋរវាងប្រទេសទាំងពីរ ។ បញ្ហានេះវាច្បាស់លាស់ហើយ យើងខ្ញុំទទួលយកខ្សែប្រេវីយេនេះក៏ដើម្បីចង់បានមិត្តភាព សាមគ្គីភាពល្អជា មួយវៀតណាមដែរ ។ តែដល់ឥឡូវនេះវៀតណាមបែរជាមិនទទួលយកខ្សែប្រេវីយេវិញ យើងក៏លំបាកដែរ មិនដឹងវៀតណាមចង់បានមិត្តភាពឬចង់បានអីទេ? ឯយើងៗ មិនអាចថយពីខ្សែប្រេវីយេនេះបានទេ ។ បើវៀត ណាមមិនទទួលខ្សែប្រេវីយេទេ យើងខ្ញុំក៏អាពិនិត្យកោះ និង ខេត្តនានានៅវៀតណាមខាងត្បូងវិញដែរ តែ បញ្ហានេះយើងខ្ញុំមិនចង់ទេ សំខាន់លើការយល់គ្នា ។ បើនិយាយតែខាងសិលធម៌ក៏ឃើញច្បាស់ថា បើវៀត ណាមមិនទទួលយកខ្សែប្រេវីយេ ហើយដីចេះតែដុះឡើងៗទៅជិតជាប់កោះ តើយើងខ្ញុំមានផ្លូវឯណាចេញចូល បាន?*

បញ្ហានេះវៀតណាមគ្មានយោគយល់ដល់យើងខ្ញុំសោះ ។ ទាល់តែមានការយោគយល់គ្នាទើបចរចារគ្នាបានផល ។
អំពីបញ្ហាព្រំដែន ជារៀងរាល់ថ្ងៃ ខាងវៀតណាមបានបាញ់កាំភ្លើងធំមកលើទឹកដីយើងខ្ញុំ ឲ្យកងទ័ពចូលឈ្លាន ពានរំលោភទឹកដីយើងខ្ញុំ ។ ប្រជាជនយើងខ្ញុំត្រូវរងគ្រោះ និង ខូចខាតទ្រព្យសម្បត្តិជាច្រើន ។ ឯដំណឹងថា ខាងស.ម. ចាប់បាន ៤០ នាក់ ហើយឆ្លើយថាយើងខ្ញុំចង់ទៅយកព្រៃនគរនោះ តើស.ម. អាចជឿបានទេ? នេះជាដំណឹងញុះញង់គ្មានសមហេតុផល ។ ទាល់តែមានមូលដ្ឋានច្បាស់លាស់ទើបអាចជឿបាន មិនមែនចេះ តែជឿៗទៅទេ ។ យើងខ្ញុំគ្មានបំណងអីទៅឈ្លានពានរំលោភទឹកដីវៀតណាមទេ ហើយផ្ទុយមកវិញក៏យើង ដាច់ខាតមិនឲ្យវៀតណាមមកឈ្លានពានរំលោភទឹកដីយើងខ្ញុំបានដែរ ។ បញ្ហានេះគួរខាងវៀតណាមពិនិត្យ មើលថែមទៀត ឯខាងយើងខ្ញុំ យើងខ្ញុំមានបំណងចង់តែមានមិត្តភាព សាមគ្គីភាពល្អជាមួយវៀតណាមទេ ។ តែយើងខ្ញុំដាច់ខាតការពារទឹកដីយើងខ្ញុំ ។ នេះជាគោលជំហររបស់យើងខ្ញុំយ៉ាងដូច្នេះ ។

<u>ការធារីវៀតណាម:</u> យើងខ្ញុំសូមមានមតិផ្ទាល់ដូចតទៅ អំពីខ្សែព្រំដែនគោគរវាងប្រទេសយើងទាំងពីរមាន ហើយដោយប្រវត្តិសាស្ត្រទុកឲ្យ ។ អម្បាញ់មិញ ស.ម. ហុង និយាយដល់ការពិនិត្យកោះ និង ខេត្តនានា នៅវៀតណាមខាងត្បូង នេះគឺផ្ទុយនឹងស.ម. ថាមិនគិតដល់រឿងចាស់ទេ ។ ឯខ្សែប្រេវីយេមិនមែនជាខ្សែព្រំដែនទេ វាគ្រាន់តែជាខ្សែចែកការអភិបាល និង ប៉ូលីសនៅលើកោះ ។ ហេតុដូច្នេះបានជាពីខែ៥ ឆ្នាំ១៩៧៦ ប្រតិភូទាំងពីរបានជួបចរចាគ្នាដើម្បីដោះស្រាយបញ្ហានេះ តែកំពុងពិភាក្សាគ្នាមិនទាន់ចប់ផង មិនទាន់សម្រេច ព្រំដែនសមុទ្រនេះទេ ។ម្យ៉ាងទៀត បើខាងស.ម. មានការលំបាក ខាងយើងខ្ញុំក៏មានការលំបាកដែរ មើល ក្នុងផែនទីគឺឃើញខ្សែប្រេវីយេរ៉ែតួតជិតកោះយើងខ្ញុំណាស់ ។ ទាល់តែមានអ្នកមានឋានៈជួបចរចាគ្នាដោយ មានផែនទីច្បាស់លាស់កំណត់សម្រេចជាមួយគ្នាទើបបាន ។ ឯយើងអង្គុយនៅទីនេះ មិនអាចសម្រេចបានទេ ។
ហើយយើងខ្ញុំមកនេះគ្រាន់តែដើម្បីបញ្ជាក់អំពីគោលជំហរយើងខ្ញុំចំពោះព្រំដែនសមុទ្រ ព្រោះការប្រជុំគ្នាពីខែ៥ ឆ្នាំ១៩៧៦ មិនទាន់សម្រេចទេ ។ ចំណែកគោលជំហររបស់បក្សយើងខ្ញុំច្បាស់លាស់ដូចដែលបានចែង ក្នុងសេចក្តីសម្រេចចិត្តនៃមហាសន្និបាតលើកទី៤ គឺរក្សាមិត្តភាពសាមគ្គីភាព..... ។ ចំពោះបញ្ហាព្រំដែន ទោះ បីមានការលំបាកស្មុគស្មាញក៏យើងខ្ញុំឈរលើគោលជំហរខាងលើដើម្បីដោះស្រាយ ។ យើងខ្ញុំគ្មានបំណងចង់ បានទឹកដីកម្ពុជាទេ ។ ឯស.ម. ហុង ថាទាល់តែមានការយល់គ្នាទើបជួបគ្នាបានផល ។ យើងខ្ញុំយល់ថាបើ មិនជួបគ្នា មិនអាចយល់គ្នាទេ ជួបគ្នាទើបយល់គ្នាបណ្តើរៗ ។ ឯបញ្ហាដែលស.ម. ហុង ថាខាងយើងខ្ញុំបាញ់កាំភ្លើងធំ និង មានការរំលោភទៅលើទឹកដីកម្ពុជានោះ គឺវាឃ្លាតឆ្ងាយពីគោលជំហរយើងខ្ញុំណាស់ តែមានករណីខ្លះបង្ខំឲ្យយើងខ្ញុំការពារខ្លួន ហើយយើងខ្ញុំយល់ថាការ ពារទឹកដីបានទើបការពារសាមគ្គីភាព មិត្តភាពបាន ។ សរុបមក យើងខ្ញុំចង់ដោះស្រាយជាក់ស្តែង ហើយមានជំនឿថាដោះស្រាយបាន ។

<u>ស.ម. ហុង:</u> យើងខ្ញុំក៏មានជំហរចង់ដោះស្រាយបញ្ហាដែរ ។ យើងខ្ញុំយល់ថាឲ្យតែគ្មានគំនិតរំលោភ

*ឈ្លានពានវាតទីលេបទឹកដី ហើយមានការយល់គ្នា គឺអាចដោះស្រាយបាន ។ ឯខ្សែប្រេវីយេធ្លាប់បាន អនុវត្តជាយូណាស់មកហើយ ជិត៤០ឆ្នាំហើយ ។ ហើយពីឆ្នាំ១៩៦៦ រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ក៏បានចាត់ទុកជាខ្សែព្រំដែនរដ្ឋដែរ ។ បញ្ហានេះគួរណាស់តែវៀតណាមយល់ បើទទួលខ្សែប្រេវីយេនេះជាព្រំ ដែនរដ្ឋ អាចដោះស្រាយបញ្ហាឯទៀតក៏បាន ។ ជាភូមិសាស្ត្រ ជាប្រវត្តិសាស្ត្រ វាច្បាស់លាស់ណាស់ទៅ ហើយ ។ បើវៀតណាមមិនទទួលយើងខ្ញុំក៏លំបាកដែរ ។ យើងខ្ញុំដាច់ខាតមិនថយពីខ្សែនេះបានទេ ។ ឯបញ្ហាសន្ធិការពារ យើងខ្ញុំមិនថាអីទេ តែដាក់ស្ពែងនៅលើសមរភូមិ ប្រជាជនយើងខ្ញុំត្រូវបានទទួលការខូច ខាតច្រើនណាស់ ។  ការច្រូតកាត់ក៏មានការលំបាក ដោយសារខាងវៀតណាមរំលោភវាតទីមកលើទឹកដីយើង ខ្ញុំ ។ សភាពការណ៍ក្តៅណាស់ មិនអាចចរចាគ្នាបានទេ ទាល់តែទុកឲ្យសភាពការណ៍ត្រជាក់សិន ទើបជួប ចរចាគ្នាបានផល ។ ម្យ៉ាងទៀត យើងខ្ញុំទទួលបានពត៌មានពីហាណូយថាមានការនិយាយអាក្រក់ពីកម្ពុជា ច្រើនណាស់ ។ នៅប៉ារីសក៏យើងខ្ញុំបានដឹងអ្នកដើរអុជអាលឲ្យពួកបារាំងដើរនិយាយមួលបង្កាច់ពីសន្ធិមនុស្ស នៅកម្ពុជា ។ អំពើទាំងនេះសុទ្ធមានបំណងចាក់រុកបង្ករឿងបំផ្លាញមិត្តភាពរវាងប្រទេសទាំងពីរ ។ ឯខាងយើង ខ្ញុំវិញ មិនដែលដើរនិយាយអីអាក្រក់ពីវៀតណាមទេ និយាយតែពីការទាក់ទងល្អ ។*

*__ការធារីវៀតណាម:__ អំពីការថាយើងខ្ញុំទៅវាតទីឈ្លានពាននោះ យើងខ្ញុំបានបដិសេធជាច្រើនលើកហើយ តែ ផ្ទុយទៅវិញទេគឺខាងកម្ពុជាទៅរំលោភឈ្លានពាន....(វារំលឹកពត៌មានវាពីលើកមុន) ។ ឯបញ្ហាចាក់រុកអុជ អាល យើងខ្ញុំគ្មានទេ ។ ការនិយាយអាក្រក់ពីកម្ពុជាក៏យើងខ្ញុំគ្មានដែរ យើងខ្ញុំមិនអាចទទួលខុសត្រូវចំពោះ ពួកចក្រពត្តិវាដើរនិយាយអាក្រក់ពីកម្ពុជាទេ ។ ចំពោះយើងខ្ញុំ ក៏វានិយាយអាក្រក់ដែរ ។*

*__ស.ម. ហុង:__ ឲ្យតែយោគយល់គ្នា មិនរំលោភឈ្លានពានលេបទឹកដីគ្នា អាចដោះស្រាយបាន ។*

*__ការធារីវៀតណាម:__ យោគយល់គ្នា ហើយមានការជួបគ្នា អាចដោះស្រាយបាន ។*

*(សម្គាល់: វាមិនហ៊ានរំលឹកដល់ពាក្យរណសិរ្សខាងត្បូងទទួលស្គាល់ខ្សែប្រេវីយេជាព្រំដែនរដ្ឋទេ) ។*